ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ១៤៣ / ២២ ជ.ក

# ផែនការប្រតិបត្តិការ

## បង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ

រហូតដល់បច្ចុប្បន្ន រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នៅតែប្តេជ្ញាចិត្តយ៉ាងមុតមាំ ប្រកបដោយឆន្ទៈមោះមុត ក្នុងការតស៊ូប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មភេទ ជាពិសេសលើស្ត្រី និងកុមារ ដើម្បីការពារជោគវាសនាប្រជាពលរដ្ឋខ្មែរទាំងក្នុង និងក្រៅប្រទេស ក៏ដូចជាជនបរទេសគ្រប់រូប ដែលរស់នៅលើព្រះរាជាណាចក្រកម្ពុជា មិនឱ្យធ្លាក់ទៅក្នុងគ្រោះមហន្តរាយដោយអំពើទាសភាព សម័យថ្មីនេះបានឡើយ។

រាជរដ្ឋាភិបាលកម្ពុជា ដោយមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ជាសេនាធិការ បានដាក់ចេញនូវបណ្តាគោលការណ៍ ផែនការ និងវិធានការជាអាទិភាព ព្រមទាំងដឹកនាំអនុវត្តកិច្ចការនេះទទួលបាននូវលទ្ធផលផ្លែផ្កាជាច្រើនគួរជាទីមោទនៈ ដែលក្នុងនោះបានលើកកម្ពស់ការយល់ដឹងរបស់សាធារណជនគ្រប់ស្រទាប់ ឲ្យបានជ្រួតជ្រាបអំពីគ្រោះថ្នាក់នៃអំពើជួញដូរមនុស្ស កលល្បិចជនល្មើស ព្រមទាំងបានបើកកិច្ចប្រតិបត្តិការយ៉ាងសកម្មក្នុងការបង្ក្រាបអំពើជួញដូរមនុស្សជាច្រើនករណី រំដោះជនរងគ្រោះច្រើនពាន់នាក់ និងបានឧបត្ថម្ភ គាំទ្រក្នុងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដោយជោគជ័យ។

ផ្តើមចេញពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល និងការធ្វើពលិកម្មយ៉ាងសកម្មរបស់ក្រសួង-ស្ថាប័នមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជួញដូរកម្លាំងពលកម្ម និងអាជីវកម្មផ្លូវភេទ បានញ៉ាំងឱ្យអំពើល្មើសទាំងនេះ ត្រូវបានកាត់បន្ថយ និងធ្វើឲ្យសង្គមកម្ពុជា មានសុខសុវត្ថិភាព សន្តិសុខ មានការរីកចម្រើន មានភាពស៊ីវិល័យសមស្របតាមគន្លងប្រពៃណី និងទំនៀមទម្លាប់ដ៏ថ្លៃថ្នូររបស់ជាតិខ្មែរ ប្រជាពលរដ្ឋមានជីវភាពសមរម្យ ដោយបានចៀសផុតពីហានិភ័យ និងគ្រោះថ្នាក់ ដែលបង្កដោយអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងជួញដូរផ្លូវភេទជាបន្តបន្ទាប់។

ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តី កម្ពុជានៅមានសេសសល់ បញ្ហាប្រឈមដោយអន្លើ ដែលបង្កឡើងដោយមហិច្ឆិតារបស់ឧក្រិដ្ឋជន រួមទាំងកត្តាសត្យានុម័តិ អត្តនោម័តិ កត្តាសេដ្ឋកិច្ច និងកត្តានយោបាយផងដែរ។ បញ្ហាទាំងអស់នេះ បានជះឥទ្ធិពលដល់កិត្យានុភាពជាតិ ប៉ះពាល់ដល់គោលនយោបាយជាយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ថែមទាំងបង្កឲ្យមានផលប៉ះពាល់ដល់សិទ្ធិ សុខុមាលភាព និងជីវភាពជាក់ស្តែងរបស់ប្រជាពលរដ្ឋមួយចំនួនទៀតផង។

អាស្រ័យហេតុនេះ ដើម្បីជំរុញឲ្យបានខ្លាំងក្លាថែមទៀតនូវសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដាក់ចេញនូវផែនការប្រតិបត្តិការ ដូចខាងក្រោម ៖

## I. គោលការណ៍រួម

១.ការពារកិត្តិយស កិត្យានុភាព និងផលប្រយោជន៍ជាតិ ប្រឆាំងរាល់ការវាយប្រហារតាមគ្រប់រូបភាពពាក់ព័ន្ធដល់ការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទនៅកម្ពុជា។

២.ចាត់វិធានការម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ជាពិសេសលើស្ត្រី និងកុមារ ឱ្យមានប្រសិទ្ធភាព រួមទាំងការចាត់វិធានការច្បាប់យ៉ាងតឹងរឹងបំផុតចំពោះអំពើជួញដូរជនបរទេសនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

៣.ពង្រឹងស្ថិរភាពសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម បង្កើតនូវបរិយាកាសសង្គមឱ្យកាន់តែល្អប្រសើរ ដើម្បីបង្កលក្ខណៈសម្បត្តិសម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យ។

៤.ប្រមូលផ្តុំកិច្ចសហការរវាងក្រសួង ស្ថាប័នជំនាញ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ តាមរយៈការប្រើប្រាស់វិធានការសរុប កម្លាំងសរុប មធ្យោបាយសរុប ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពតាមស្មារតីនៃផែនការនេះ។

## II. វិធានការអនុវត្ត

ក្រសួង ស្ថាប័នជំនាញ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ និងគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត ត្រូវយកចិត្តទុកដាក់ខ្ពស់ ក្នុងកិច្ចសហការអនុវត្តនូវវិធានការសំខាន់ៗ ដូចខាងក្រោម ៖

### ១. ការងារផ្សព្វផ្សាយអប់រំ

- បង្កើនសកម្មភាពផ្សព្វផ្សាយអប់រំដល់សាធារណជនទូទៅ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសភាពការណ៍ ល្បិចកល សកម្មភាពឧក្រិដ្ឋជនជួញដូរមនុស្ស និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ជាពិសេសលើស្ត្រី និងកុមារ នាពេលកន្លងមក និងការបន្តពុះពារអនុវត្តកិច្ចការនេះ សំដៅការពារកិត្តិយស សេចក្តីថ្លៃថ្នូរ និងជីវភាពរស់នៅល្អប្រសើរសម្រាប់ប្រជាពលរដ្ឋខ្មែរគ្រប់រូប។

- លើកកម្ពស់សកម្មភាពផ្សព្វផ្សាយអប់រំ ការយល់ដឹងអំពីច្បាប់ស្តីពីការងារ ច្បាប់ស្តីពីការប្រឆាំងការជួញដូរមនុស្ស និងកម្លាំងពលកម្ម ច្បាប់ស្តីពីអន្តោប្រវេសន៍ និងច្បាប់បទដ្ឋានគតិយុត្តិចាំបាច់នានាឱ្យបានជ្រួតជ្រាបក្នុងស្រទាប់មហាជនគ្រប់ជាន់ថ្នាក់ សំដៅបំផុសចលនាឲ្យចូលរួមគោរព និងអនុវត្តច្បាប់ ឲ្យបានល្អប្រសើរ។

- ជំរុញការផ្សព្វផ្សាយគោលនយោបាយ «ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព» ឲ្យកាន់តែសកម្មផុលផុសបន្ថែមទៀត ដើម្បីបង្កើនការយល់ដឹងឲ្យកាន់តែទូលំទូលាយ និងបំផុសឲ្យមានការចូលរួមប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទនៅកម្ពុជា ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

## ២. ការអនុវត្តវិធានការរដ្ឋបាល

- ពង្រឹងការងារកំណត់អត្តសញ្ញាណបណ្តាគោលដៅ ទីតាំងដែលអាចសន្មត់ថា ជាកន្លែងប្រព្រឹត្ត អំពើជួញដូរមនុស្ស (គោលដៅងាយរងគ្រោះ) ឱ្យបានហ្មត់ចត់ សំដៅមានវិធានការគ្រប់គ្រង បង្ការ ទប់ស្កាត់ និងបង្រ្កាបប្រកបដោយប្រសិទ្ធភាព។

- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ចុះត្រួតពិនិត្យដល់ទីកន្លែង ឬកោះអញ្ជើញ ម្ចាស់ ឬអ្នកគ្រប់គ្រងគោលដៅងាយរងគ្រោះ ដើម្បីធ្វើការណែនាំឲ្យយល់អំពីឆន្ទៈ និងការប្តេជ្ញាចិត្តដ៏មោះមុត របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ក៏ដូចជាការប្រឈមទៅ នឹងវិធានការរដ្ឋបាល និងវិធានការច្បាប់ ចំពោះគោលដៅអាជីវកម្មនានា ដែលប្រព្រឹត្តល្មើសនឹងគោលការណ៍ ច្បាប់ ដោយតម្រូវឲ្យម្ចាស់ទីកន្លែង ឬអ្នកគ្រប់គ្រងទាំងនោះ ធ្វើលិខិតប្រកាសការប្តេជ្ញាចិត្តរបស់ខ្លួន (ឬកិច្ច សន្យា) ដើម្បីធានាមិនឲ្យកើតមានបទល្មើសទាំងនោះនៅក្នុងគោលដៅអាជីវកម្ម សេវាកម្មរបស់ខ្លួន។ ក្នុង ករណីដែលរកឃើញថា មានការប្រព្រឹត្តបទល្មើសក្នុងទីតាំងរបស់ខ្លួន ម្ចាស់ទីតាំងនោះ និងជនល្មើស ត្រូវ ប្រឈមនឹងការផ្តន្ទាទោសតាមផ្លូវច្បាប់។

- ពង្រឹងវិធានការគ្រប់គ្រង និងត្រួតពិនិត្យសកម្មភាពរបស់បណ្តាទីភ្នាក់ងារជ្រើសរើសឯកជន (ក្រុមហ៊ុនជ្រើសរើសពលករ) ដើម្បីតម្រង់ទិសអនុវត្តឲ្យបានត្រឹមត្រូវតាមគោលការណ៍របស់រាជរដ្ឋាភិបាល កម្ពុជា និងរកឃើញទាន់ពេលនូវសកម្មភាពល្មើសនានាពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ដើម្បីចាត់វិធានការ ច្បាប់ឲ្យបានម៉ឺងម៉ាត់។ (ដូចក្នុងអនុសាសន៍នៃផែនការសកម្មភាព ចំណុចទី ១០ និងទី ១៥)

- ចាត់វិធានការត្រួតពិនិត្យរដ្ឋបាល ឬត្រួតពិនិត្យដោយចៃដន្យដោយមិនចាំបាច់ជូនដំណឹង ចំពោះ ទីតាំងអាជីវកម្ម សេវាកម្មគ្រប់ប្រភេទរបស់ជនជាតិខ្មែរ ឬ/និងជនបរទេសដែលមានការសង្ស័យ និងមាន ព័ត៌មានជាក់លាក់ សំដៅរកឃើញជនបរទេសស្នាក់នៅ ឬ/និងបម្រើការងារ ក៏ដូចជាការប្រកបអាជីវកម្ម សេវា កម្មដោយខុសច្បាប់ ដើម្បីមានចំណាត់ការសមស្របតាមច្បាប់ជាធរមាន។ (សម្រួលតាមខ្លឹមសារអនុសាសន៍ នៃផែនការសកម្មភាព ចំណុចទី ៥)

- ពង្រឹងការគ្រប់គ្រង និងត្រួតពិនិត្យការធ្វើដំណើរចូល-ចេញ ឆ្លងកាត់ព្រំដែនឱ្យបានហ្មត់ចត់ ក្នុង នោះយកចិត្តទុកដាក់ការងារប្រមែប្រមូលព័ត៌មាន ដើម្បីស្រាវជ្រាវ បង្រ្កាបអំពើជួញដូរមនុស្សនៅតាមច្រកទ្វារ ព្រំដែនឱ្យមានប្រសិទ្ធភាព ជាមួយនោះបង្កើនសកម្មភាពយាមល្បាត ការពារខ្សែបន្ទាត់ព្រំដែនគោក-ទឹក សំដៅទប់ស្កាត់ការជ្រៀតចូលដោយខុសច្បាប់តាមរបៀងនានារបស់ជនបរទេស មកក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងយកចិត្តទុកដាក់ស្រាវជ្រាវ បង្រ្កាបយ៉ាងម៉ឺងម៉ាត់ បណ្តាញខ្សែរយៈជួញដូរមនុស្សឆ្លងកាត់ព្រំដែន។

## ៣. ការអនុវត្តវិធានការច្បាប់

- ជំរុញការងារស្រាវជ្រាវ ស៊ើបអង្កេត រកទីតាំងប្រព្រឹត្តបទល្មើសគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម អាជីវកម្មផ្លូវភេទ ការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ បទល្មើសបង្ខាំងមនុស្ស ខុសច្បាប់ ចាប់ជំរិតមនុស្សទារប្រាក់ ការបង្ខំឲ្យធ្វើពលកម្ម និងបទល្មើសអន្តោប្រវេសន៍ ដើម្បីបង្រ្កាប ចាប់ខ្លួន មេខ្លោង និងបក្ខពួក ផ្តន្ទាទោសតាមច្បាប់ និងសង្គ្រោះជនរងគ្រោះឲ្យបានទាន់ពេលវេលា។ (គ្របដណ្តប់លើ ខ្លឹមសារអនុសាសន៍នៃផែនការសកម្មភាព ចំណុចទី ១ និងចំណុចទី ៦)

- ជំរុញសកម្មភាពសវនាការជំនុំជំរះបណ្តឹងករណីបទល្មើសជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ឱ្យអស់ពីលទ្ធភាព និងធ្វើការផ្តន្ទាទោសយ៉ាងតឹងរ៉ឹង គ្មានការបន្ធូរបន្ថយ និងគ្មានការលើកលែង ដោយមានការលើកទឹកចិត្តឲ្យចូលរួមពីជនរងគ្រោះជាពលរដ្ឋខ្មែរ ឬជនបរទេស ព្រមទាំងមានការត្រួតពិនិត្យ ប្រមូលទិន្នន័យស្តីពីការកាត់ទោសឲ្យបានគ្រប់ជ្រុងជ្រោយ។ (សម្រួលតាមខ្លឹមសារអនុសាសន៍នៃផែនការសកម្មភាព ចំណុចទី ៨ និងទី ៩)

- បង្កើនការងារស្រាវជ្រាវ ស៊ើបអង្កេត ពន្លាតនីតិវិធីរកផលសម្អាងនៃបទល្មើស ដើម្បីប្រឆាំងការសម្អាតប្រាក់ និងអំពើជួញដូរមនុស្ស។

- បង្កើនការផ្លាស់ប្តូរព័ត៌មានរវាងស្ថាប័នតុលាការ និងអាជ្ញាធរ ឬអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីសម្រួលដល់កិច្ចការត្រួតពិនិត្យ ជនជាប់ចោទ ដែលដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ រង់ចាំការកាត់ក្តី។ (បន្ថែមខ្លឹមសារឲ្យស្របតាមអនុសាសន៍នៃផែនការសកម្មភាព ចំណុចទី ៤)

### ៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ

- បង្កើនកិច្ចសហការជាមួយសមត្ថកិច្ចអនុវត្តច្បាប់នៃប្រទេសជាមិត្ត ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី ដើម្បីបង្កើតយន្តការទំនាក់ទំនងផ្លាស់ប្តូរព័ត៌មានតាមគ្រប់មធ្យោបាយ គ្រប់រូបភាព ស្តីពីសភាពការណ៍ សកម្មភាព និងល្បិចកលមុខសញ្ញាទាក់ទិនដល់គ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ បទល្មើសបង្ខាំងមនុស្សខុសច្បាប់ ចាប់ជំរិតមនុស្សទារប្រាក់ បទល្មើសអន្តោប្រវេសន៍ និងការលួចលាក់ប្រើប្រាស់កម្លាំងពលកម្មជនបរទេសដោយខុសច្បាប់ សំដៅចាត់វិធានការសមស្រប ទាន់ពេលវេលា។

- សហការស្រាវជ្រាវ ស៊ើបអង្កេត ដោយអនុលោមទៅតាមច្បាប់ជាធរមាន ដើម្បីរកឃើញ និងបង្ក្រាបប្រកបដោយប្រសិទ្ធភាពនូវខ្សែរយៈ និងបណ្តាញប្រព្រឹត្តអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ បទល្មើសបង្ខាំងមនុស្សខុសច្បាប់ ចាប់ជំរិតមនុស្សទារប្រាក់ បទល្មើសអន្តោប្រវេសន៍ ការលួចលាក់ប្រើប្រាស់កម្លាំងពលកម្មជនបរទេសដោយខុសច្បាប់។

- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូប្រកបដោយលក្ខណៈស៊ីជម្រៅ និងភាពស្មោះត្រង់ជាមួយបណ្តាអង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងនៅក្នុងក្របខ័ណ្ឌគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា សំដៅទាក់ទាញនូវការចូលរួមគាំទ្រក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ឱ្យកាន់តែទទួលបានលទ្ធផលល្អប្រសើរ។

### ៥. ការងារសាធារណមតិ

- រៀបចំវេទិកាសាធារណៈ ឬសន្និសីទសារព័ត៌មានឱ្យបានញឹកញាប់ ដើម្បីធ្វើការផ្សព្វផ្សាយជូនសាធារណជនឲ្យបានដឹងអំពីលទ្ធផលនានា ដែលសម្រេចបានក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ សំដៅបង្ហាញឱ្យឃើញពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងប្រតិកម្មឆ្លើយតបទាន់ពេលវេលាចំពោះព័ត៌មានអគតិ។

- រៀបចំបង្កើតប្រព័ន្ធ Hotline សម្រាប់សាធារណជនទាក់ទងសួរនាំ ផ្តល់ព័ត៌មាន ឬចូលរួមយោបល់ក្នុងដំណើរការការងារប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ។

III. **ការចាត់តាំងអនុវត្ត**

ផែនការនេះត្រូវបានចាត់ទុកថា ជាផែនការប្រតិបត្តិការរបស់កងកម្លាំងអនុវត្តច្បាប់ ដោយមានកិច្ចសហការពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព អាជ្ញាធរពាក់ព័ន្ធ ដើម្បីប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ និងការលួចលាក់ប្រើប្រាស់កម្លាំងពលកម្មជនបរទេសដោយខុសច្បាប់ ដែលជាចំណែកមួយនៃការអនុវត្តផែនការរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលបានដាក់ចេញកន្លងមក។

ដើម្បីអនុវត្តផែនការនេះ ឲ្យទទួលបានជោគជ័យត្រូវ ៖

១. បង្កើត **គណៈបញ្ជាការដឹកនាំប្រតិបត្តិការ** ដែលមានសមាសភាព :

- ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ជាប្រធាន
- ឯកឧត្តម នាយឧត្តមសេនីយ៍ **សៅ សុខា** អគ្គមេបញ្ជាការរង ខ.ភ.ម និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ជាអនុប្រធាន
- ឯកឧត្តម នាយឧត្តមសេនីយ៍ **គៀត ច័ន្ទថារិទ្ធ** អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ជាអនុប្រធាន
- ឯកឧត្តម **សេង សក្ដា** អគ្គនាយក នៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាអនុប្រធាន
- ឯកឧត្តម **ជុំ កុសល** រដ្ឋលេខាធិការ ក្រសួងព័ត៌មាន ជាសមាជិក
- លោកជំទាវ **ឡុង សុនីតា** សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ជាសមាជិក
- ឯកឧត្តម **ប៉ែន ពេជ្រសាលី** អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ ជាសមាជិក
- ឯកឧត្តម ឧត្តមសេនីយ៍ទោ **តែ សុថារ៉េត** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសមាជិក
- លោក **ឡោ ធូរ៉ា** អគ្គនាយករង នៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ ក្រសួងទេសចរណ៍ ជាសមាជិក
- លោក **រស់ គីរុណា** អគ្គនាយករង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា ជាសមាជិក
- លោក **ជ័យ រដ្ឋា** ប្រធាននាយកដ្ឋានកិច្ចការកុងស៊ុល នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក
- ឯកឧត្តម **ឌិត សុធា** អនុប្រធានប្រចាំការ អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស នៃទីស្ដីការគណៈរដ្ឋមន្ត្រី ជាសមាជិក

- ឧត្តមសេនីយ៍ឯក **សៀង សេន** ប្រធាននាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម និងជាលេខាធិការអចិន្ត្រៃយ៍ នៃគណៈកម្មការចម្រុះបង្ក្រាបការលេងល្បែងកាស៊ីណូ ឆ្នោត-ឡូតូ ភ្នាល់បាល់ ភ្នាល់អនឡាញ និងល្បែងភ្នាល់ខុសច្បាប់គ្រប់ប្រភេទ ជាសមាជិក

- ឯកឧត្តម អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ជាសមាជិក

២. ផ្អែកលើផែនការនេះ គណៈបញ្ជាការដឹកនាំប្រតិបត្តិការ ត្រូវកសាងផែនការដាក់ស្តែង បម្រើឲ្យប្រតិបត្តិការបង្ក្រាប និងការសង្គ្រោះជនរងគ្រោះ ដើម្បីចង្អុលដឹកនាំឱ្យមានប្រសិទ្ធភាពនូវគោលការណ៍ និងវិធានការដែលបានកំណត់។ (សម្រួលតាមគោលបំណងរួមរបស់អនុសាសន៍នៃផែនការសកម្មភាព ដើម្បីគាំពារជនរងគ្រោះ)

៣. គណៈបញ្ជាការដឹកនាំប្រតិបត្តិការ ត្រូវធ្វើរបាយការណ៍បូកសរុបលទ្ធផលអនុវត្តផែនការនេះតាមការកំណត់ និងដោយចែជន្យជូនប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីមានគោលការណ៍ចង្អុលដឹកនាំ និងណែនាំ ប្រកបដោយប្រសិទ្ធភាព។

ក្នុងករណីចាំបាច់ អាចបង្កើតលេខាធិការដ្ឋាន ដើម្បីជាសេនាធិការ ក្នុងការតាមដាន ត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការអនុវត្តផែនការនេះ។

៤. មានកម្មវិធីបណ្តុះបណ្តាល លើកកម្ពស់សមត្ថភាពមន្ត្រីអនុវត្តច្បាប់ ព្រមទាំងមានការលើកសរសើរជូនរង្វាន់លើកទឹកចិត្តចំពោះអង្គភាព និងបុគ្គលដែលមានស្នាដៃល្អក្នុងការអនុវត្តផែនការនេះ និងមានវិធានការដាក់វិន័យម៉ឺងម៉ាត់បំផុតចំពោះបុគ្គលប្រព្រឹត្តខុសឆ្គង ឬអសកម្ម។

៥. លើកផែនការស្នើថវិកា មធ្យោបាយ សម្ភារ បរិក្ខាចាំបាច់ ដើម្បីធានាក្នុងការអនុវត្តផែនការនេះ។

ក្រសួង ស្ថាប័នដែលជាសមាជិកនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ក្រុមការងាររាជរដ្ឋាភិបាលចុះជួយមូលដ្ឋានគ្រប់ថ្នាក់ រដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ ឃុំ-សង្កាត់ និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវចាត់តាំងអនុវត្តផែនការនេះ ប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ១០កើត ខែ ស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០២២

**ប្រធានគណៈកម្មាធិការជាតិ**

**ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**សម្តេចក្រឡាហោម ស ខេង**